# សេចក្តីថ្លែងការណ៍រួម

## រដ្ឋាភិបាលកម្ពុជាត្រូវតែបញ្ឈប់ចំបិទសំឡេងអ្នកសារព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

*ដោះលែងអ្នកធ្វើការក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលត្រូវបានឃាត់ខ្លួនអោយមានសេរីភាពឡើងវិញ និងផ្តល់អាជ្ញាប័ណ្ណទៅប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឡើងវិញ*

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០២០

យើងខ្ញុំជាអង្គការសង្គមស៊ីវិលចំនួន ៥៧ ដែលមានឈ្មោះដូចខាងក្រោម សូមសម្តែងការព្រួយបារម្ភអំពីការឃាយីរបស់រដ្ឋាភិបាលកម្ពុជាទៅលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យនិងអ្នកសារព័ត៌មាន។ រដ្ឋាភិបាលគួរតែទម្លាក់ចោលការចោទប្រកាន់ដោយហេតុផលនយោបាយទៅលើអ្នកសារព័ត៌មាន ហើយដោះលែងពួកគេដោយគ្មានលក្ខខណ្ឌ។ ច្បាប់ដែលមានលក្ខណៈគាបសង្កត់ រារាំងសេរីភាពសារព័ត៌មាន និងសេរីភាពក្នុងការបញ្ចេញមតិដែលមិនសមហេតុផលគួរត្រូវលុបចោលឬកែប្រែ។ រដ្ឋាភិបាលក៏គួរតែបញ្ឈប់ជាបន្ទាន់នូវការដកហូតអាជ្ញា ប័ណ្ណរបស់បណ្តាញផ្សព្វផ្សាយព័ត៌មានឯករាជ្យ ហើយនឹងមិនដកហូតអាជ្ញាប័ណ្ណនេះតទៅទៀតទេនៅពេល អនាគត។

បច្ចុប្បន្ននេះ រដ្ឋាភិបាលកម្ពុជាកំពុងឃុំខ្លួនអ្នកសារព័ត៌មានចំនួន២ នាក់ដោយចោទប្រកាន់ពីបទញុះញង់ឬពីបទបរិហារកេរ្តិ៍ដូចជាលោក **សុខ ឧត្តម** លោក **រស់ សុឃិត** ។ អ្នកកាសែតទី ៣ គឺលោក **វ៉ាត់ វ័ត្ន មុន្នី** កំពុងជាប់ពន្ធនាគាររយៈពេល២ ឆ្នាំក្រោមបទចោទប្រកាន់ស្រដៀងគ្នា។

១. នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ការិយាល័យប្រឆាំងឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធឺណិតរបស់ស្នងការនគរបាលរាជធានីភ្នំពេញបានចាប់ខ្លួនលោក **រស់ សុឃិត** ជាអ្នកបោះពុម្ពកាសែតជាតិខ្មែរ (ជាតិខ្មែរ) ដោយសារតែការបង្ហោះនៅក្នុងទំព័រហ្វេសប៊ុករបស់លោកចំនួនពីរដងដែលលើកឡើងពីផែនការបន្តបន្ទាប់របស់លោកនាយករដ្ឋមន្ត្រីនិងវិបត្តិបំណុលខ្នាតតូចនៅកម្ពុជា។ អាជ្ញាធរបានចោទប្រកាន់លោកពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ហើយបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារព្រៃសរាជធានីភ្នំពេញ។ ក្រសួងព័ត៌មានដែលបានផ្តល់អាជ្ញាប័ណ្ណដល់សារព័ត៌មាន*ជាតិខ្មែរ* នៅខែមេសា ឆ្នាំ២០២០ នេះបានប្រកាសថានឹងពិនិត្យឡើងវិញនូវអាជ្ញាប័ណ្ណនេះ ដោយផ្អែកតាមការចោទប្រកាន់របស់តុលាការ។

២. នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ ប៉ូលីសបានចាប់ខ្លួនលោក **សុខ ឧត្តម** ជាម្ចាស់ស្ថានីយ៍វិទ្យុនិងគេហទំព័រក្នុងខេត្តកំពង់ឆ្នាំងដោយចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ដោយរាយការណ៍អំពីជំលោះដីធ្លីដូចគ្នានៅដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ខេត្តកំពង់ឆ្នាំង ដូចគ្នានឹងលោក **កែវ ហួរ** អ្នកសារព័ត៌មានតាមគេហទំព័រ*ស្នេហាជាតិ*ដែរ ហើយតុលាការក៏បានចោទប្រកាន់លោកពីបទឧក្រិដ្ឋដូចគ្នាផងដែរ។ បច្ចុប្បន្ននេះលោក សុខ ឧត្តម ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្តកំពង់ឆ្នាំង។ លោកសុខ ឧត្តម តែងតែបានរាយការណ៍អំពីជំលោះដីធ្លីដែលមានជាយូរមកហើយរវាងសហគមន៍កសិកម្មមូលដ្ឋាននិងមន្ត្រី ដែលមានអំណាច។

៣. នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨ អាជ្ញាធរថៃបានចាប់ខ្លួនលោក **រ៉ាត់ រ័ត្នមុន្នី** ដែលជាអ្នកបកប្រែអោយសារព័ត៌មានរបស់ប្រទេសរុស្ស៊ីឈ្មោះ *រុស្ស៊ីធូដេយ* ដោយផ្អែកតាមសំណើរបស់រដ្ឋាភិបាលកម្ពុជាដែលបានចោទប្រកាន់ថាលោកបានប្រព្រឹត្តិការញុះញង់ នៅពេលធ្វើការជាមួយ*រុស្ស៊ីធូដេយ*លើឯកសារដែលបង្ហាញពីភាពក្រីក្ររបស់ក្រុមគ្រួសាររងគ្រោះដែលបញ្ជូនកូនស្រីរបស់ខ្លួនអោយចូលរួមក្នុងការជួញដូរផ្លូវភេទកុមារ។ នៅថ្ងៃទី១២ ខែធ្នូ គាត់ត្រូវបានបញ្ជូនមកប្រទេសកម្ពុជាហើយបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ន។ កាលពីខែមិថុនា ឆ្នាំ២០១៩ តុលាការក្រុងភ្នំពេញបានផ្តន្ទាទោសគាត់ពីបទញុះញង់ឱ្យមានការរើសអើង (មាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌកម្ពុជា) និងផ្តន្ទាទោសគាត់ឱ្យជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ។ នៅខែមិថុនាឆ្នាំ ២០២០ តុលាការកំពូលបាន[សម្រេច](#)ឱ្យមានការជំនុំជម្រះក្តីឡើងវិញរបស់លោក រ៉ាត់ រ័ត្នមុន្នី ដោយរកឃើញថាការផ្តន្ទាទោសរបស់គាត់គឺមិនត្រឹមត្រូវ។

នៅក្នុងករណីពិសេសមួយផ្សេងទៀត ដែលបង្ហាញពីការឃាយីឥតឈប់ឈររបស់ប្រទេសកម្ពុជាទៅលើសេរីភាពសារព័ត៌មាននោះគឺ កាលពីថ្ងៃទី៥ ខែតុលា សាលាដំបូងរាជធានីភ្នំពេញបានកាត់ទោសអ្នកសារព័ត៌មានលោក សុវណ្ណ រិទ្ធី នាយកស្ថានីយទូរទស្សន៍ TVFB ពីបទញុះញង់និងផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល ១៨ ខែ។ រយៈពេល ៥ ខែនិង២៨ ថ្ងៃដែលគាត់បានជាប់នៅក្នុងការឃុំខ្លួនបណ្តោះអាសន្នត្រូវបានកាត់កង ហើយតុលាការសម្រេចព្យួរទោសចំនួនថ្ងៃដែលនៅសេសសល់។ បន្ទាប់មក គាត់ត្រូវបានគេដោះលែងពីពន្ធនាគារនៅថ្ងៃដដែល។ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២០ នគរបាលរាជធានីភ្នំពេញបានចាប់ខ្លួនលោក សុវណ្ណ រិទ្ធី ដោយផ្អែកលើការចោទប្រកាន់ថាលោកបានញុះញង់ឱ្យមានភាពវឹកវរ តាមរយៈការដកស្រង់ពាក្យពេចន៍ចេញពីសុន្ទរកថារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃទី៧ ខែមេសា នៅលើទំព័រហ្វេសបុករបស់ខ្លួនអំពីផលប៉ះពាល់ខាងសេដ្ឋកិច្ចដោយសារជំងឺរាតត្បាតកូវីដ១៩ថា៖ "ប្រសិនបើអ្នករត់ម៉ូតូឌុប អ្នកបើកបរតាក់ស៊ីក្ស័យធន លក់ម៉ូតូរបស់អ្នកចាយសិនទៅ។ រដ្ឋាភិបាលមិនមានសមត្ថភាពជួយទេ។"

យោងតាម[របាយការណ៍](#)របស់អង្គការមិនមែនរដ្ឋាភិបាលបានបង្ហាញថានៅចន្លោះខែមករានិងឧសភា ឆ្នាំ២០២០ ប៉ូលីសនិងអាជ្ញាធរយុត្តិធម៌កម្ពុជាបានកោះហៅនិងសាកសួរយ៉ាងហោចណាស់អ្នកសារព័ត៌មានជាងដប់នាក់ដោយសារតែការរាយការណ៍របស់ពួកគេ។

អ្នកសារព័ត៌មានឯករាជ្យត្រូវបានអាជ្ញាធរយាយីជាយូរមកហើយ ជាពិសេសនៅពេលរាយការណ៍អំពីការរិះគន់រដ្ឋាភិបាល។ អតីតអ្នកកាសែត*វិទ្យុអាស៊ីសេរី* ពីររូបគឺលោក **យិន សុធារិទ្ធ** និងលោក **អ៊ួន ឈិន**នៅតែប្រឈមការចោទប្រកាន់ពីបទចារកម្មដោយផ្អែកលើការចោទប្រកាន់ដោយគ្មានភស្តុតាងថាពួកគេបានឃុបឃិតជាមួយរដ្ឋាភិបាលបរទេស។ អតីតអ្នកកាសែត*ខេមបូឌៀដេលី* ពីរនាក់គឺលោក Zsombor Peter និងលោក **អូន ភាព** ប្រឈមនឹងការកាត់ទោសកំបាំងមុខ ដោយចោទប្រកាន់ពីបទញុះញង់គ្មានមូលដ្ឋាន និងអ្នកយកព័ត៌មានទូរទស្សន៍លេខ ៣ គឺលោក **ផល ដាំ** ប្រឈមនឹងការចោទប្រកាន់ពីបទញុះញង់ដោយគ្មានមូលដ្ឋានសម្រាប់ការរាយការណ៍អំពីបញ្ហាទាក់ទងនឹងដីធ្លី។

យ៉ាងហោចណាស់មានករណីរំលោភបំពានលើអ្នកសារព័ត៌មានចំនួន ៩ ករណីផ្សេងទៀតត្រូវបានកត់ត្រាចាប់តាំងពីឆ្នាំ ២០១៩ ក្នុងនោះមានករណីលោក**កែវ ហួរ** អ្នកសារព័ត៌មានតាមគេហទំព័រ *ស្នេហាជាតិ* ដែលអាជ្ញាធរបានដោះលែង ឲ្យ នៅក្រៅឃុំដោយមិនទម្លាក់ការចោទប្រកាន់ពីបទញុះញង់ លោក ហ៊ុន សុខា ប្រធានក្លឹបអ្នកសារព័ត៌មានឯករាជ្យ លោក កែវ រតនា អ្នកបោះពុម្ពផ្សាយ*ជីអិនអនឡាញ*។ លោក **ប្រាក់ សុវណ្ណ** អ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី និងលោក **សាត ចាន់បុត្រ** អ្នកកាសែតវិទ្យុអាស៊ីសេរីនិងទូរទស្សន៍អប្សរា។

ចាប់តាំងពីការផ្ទុះឡើងនៃជំងឺរាតត្បាតកូវីដ១៩ មក រដ្ឋាភិបាលបានដកហូតអាជ្ញាប័ណ្ណផ្សព្វផ្សាយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យចំនួនបួនគឺគេហទំព័រព័ត៌មានអនឡាញ*CKV TV Online* ស្ថានីយ៍វិទ្យុរិទ្ធិសែន និងគេហទំព័រព័ត៌មានអនឡាញ និងគេហទំព័រព័ត៌មាន TVFB។ កាលពីខែមេសា ក្រសួងព័ត៌មានបានដកហូតអាជ្ញាប័ណ្ណរបស់*CKV TV Online*ដោយចោទប្រកាន់ ថាបានរំលោភលើវិជ្ជា ជីវៈសារព័ត៌មានដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។ ស្រដៀងគ្នានេះដែរ ក្រសួងព័ត៌មានបានដកហូតអាជ្ញាប័ណ្ណស្ថានីយ៍វិទ្យុរិទ្ធិសែន រួមជាមួយនឹងអាជ្ញាប័ណ្ណគេហទំព័រព័ត៌មានដាច់ដោយឡែកពីគ្នា ដោយចោទប្រកាន់ដោយគ្មានភស្តុតាងថាវិទ្យុនេះផ្សព្វផ្សាយព័ត៌មានដែលជាព័ត៌មានបំផ្លើសមាន ការញុះញង់ឱ្យមានអំពើហិង្សា ញុះញង់ឱ្យមានការរើសអើង និងបង្កហេតុ បង្កអសន្តិសុខសង្គមនិងភាពវឹកវរ។ លើសពីនេះទៀតក្រសួងព័ត៌មានបានដកហូតអាជ្ញាប័ណ្ណផ្សាយរបស់ទូរទស្សន៍ TVFB ដោយហេតុផលថាព័ត៌មានដែលបានផ្សព្វផ្សាយគឺដើម្បីបង្កើតផលប៉ះពាល់អវិជ្ជមានដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម។

រដ្ឋាភិបាលកម្ពុជាបានធ្វើទុកបុកម្នេញយ៉ាងខ្លាំងទៅលើសេរីភាពសារព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិចាប់តាំងពីពាក់កណ្ដាលឆ្នាំ២០១៧ មក។ រដ្ឋាភិបាលបានបង្ខំឱ្យបិទកាសែត*ឌឹខេមបូឌៀដេលី* ដែលជាកាសែតមួយក្នុងចំណោមកាសែតឯករាជ្យចេញផ្សាយប្រចាំថ្ងៃជាភាសាអង់គ្លេស ។ កាសែតភ្នំពេញប៉ុស្តិ៍ត្រូវបានលក់ចេញកាលពីខែឧសភា ឆ្នាំ២០១៨ ទៅពាណិជ្ជករម្នាក់ដែលមានទំនាក់ទំនងជាមួយលោកនាយករដ្ឋមន្ត្រី ហើយចាប់តាំងពីពេលនោះមកកាសែតភ្នំពេញប៉ុស្ដិ៍បានឆ្លុះបញ្ចាំងតែពីតួនាទីរបស់រដ្ឋាភិបាលនៅក្នុងការបោះពុម្ពផ្សាយរបស់ខ្លួនជាច្រើន។ កាលពីខែសីហា ឆ្នាំ២០១៧ អាជ្ញាធរកម្ពុជាបានបញ្ជាឱ្យបិទប្រេកង់វិទ្យុអេហ្វអឹម ចំនួន ៣២ស្ថានីយនៅទូទាំងខេត្តចំនួន២០ ដែលជាស្ថានីយផ្សព្វផ្សាយបន្តព័ត៌មានភាសាខ្មែររបស់*វិទ្យុអាស៊ីសេរី វិទ្យុសំឡេងសហរដ្ឋអាមេរិក* (វីអូអេ)និង*វិទ្យុសំឡេងប្រជាធិបតេយ្យ* (វីអូឌី)។ វិទ្យុអាស៊ីសេរីបានបិទការិយាល័យរបស់ខ្លួននៅរាជធានីភ្នំពេញក្នុងខែកញ្ញា ឆ្នាំ២០១៧ បន្ទាប់ពីប្រតិបត្តិការអស់រយៈពេល ២០ ឆ្នាំនៅកម្ពុជា ដោយខ្លាចមានការគំរាមកំហែងដល់បុគ្គលិករបស់ខ្លួន។ ពីរបីថ្ងៃបន្ទាប់ពីការបិទការិយាល័យវិទ្យុអាស៊ីសេរី ក្រសួងមហាផ្ទៃបានគំរាមអ្នកកាសែតដែលបានធ្វើការឱ្យវិទ្យុអាស៊ីសេរី ថានឹងមានវិធានការផ្លូវច្បាប់ប្រសិនបើពួកគេបន្តរាយការណ៍ព័ត៌មានទៅអោយវិទ្យុអាស៊ីសេរីបន្តទៀត។

ក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ រដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ដែលមានលក្ខណៈរឹតត្បិតជាបន្តបន្ទាប់ដែលជំរុញឱ្យមានការបង្ក្រាបទៅលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យនិងបណ្តាញផ្សព្វផ្សាយសង្គមហើយបាន

ប្រើបទប្បញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌជាពិសេសមាត្រា ៤៩៤ និង ៤៩៥ ដើម្បីបំបិទសំឡេងសេចក្តីរាយការណ៍ដែលមិនស្របនិងបំបិទសំឡេងអ្នកយកព័ត៌មាន។

ក្នុងអំឡុងពេលមានវិបត្តិនៃការរាតត្បាតជំងឺកូវីដ១៩ រដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ដ៏តឹងរ៉ឹងមួយស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្នដែលផ្តល់ឱ្យលោកនាយករដ្ឋមន្ត្រីនូវអំណាចដោយគ្មានកំណត់និងទូលំទូលាយដើម្បីតាមដានរាល់ការទំនាក់ទំនងឯកជន និងការរឹតត្បិតការរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ យើងខ្ញុំក៏បានដឹងផងដែរថារដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្តីព្រាងអនុក្រឹត្យអំពីច្រកចេញចូលអ៊ីនធឺណិតដែលមិនទាន់ត្រូវបានអនុម័តនៅឡើយ ដែលនេះនឹងអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់សេរីភាពនៃការបញ្ចេញមតិនិងទទួលព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណិត ដែលសម្រួលដល់ការឃ្លាំមើលរាល់ការទំនាក់ទំនងតាមប្រព័ន្ធអ៊ីនធឺណិតនិងអនុញ្ញាតឱ្យអាជ្ញាធរអាចបិទនូវខ្លឹមសារ មាតិកា ប្រសិនបើមាតិកាទាំងនោះត្រូវបានចាត់ទុកថា"ប៉ះពាល់ដល់សុវត្ថិភាព ចំណូលជាតិ សណ្តាប់ធ្នាប់សង្គម សេចក្តីថ្លៃថ្នូរ វប្បធម៌ប្រពៃណីនិងទំនៀមទម្លាប់" ។

ប្រទេសកម្ពុជាបានទទួលស្គាល់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅឆ្នាំ ១៩៩២ ដែលត្រូវមានកាតព្វកិច្ចធានា ការគោរព និងការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនិងគំនិតដោយគ្មានការរើសអើង និងសិទ្ធិក្នុងការស្វែងរក ទទួល និងចែកចាយព័ត៌មាន និងគំនិតតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានណាមួយនិងដោយមិនគិតពីព្រំដែន។ ការរឹតត្បិតណាមួយចំពោះសិទ្ធិទាំងនេះត្រូវតែធ្វើឡើងប្រកបដោយយុត្តិធម៌និងស្របច្បាប់ក្នុងភាពចាំបាច់ និងសមាមាត្រដោយគោរពទៅតាមគោលបំណងនៃច្បាប់។ រាល់ករណីដែលបានលើកឡើងខាងលើ គ្មានករណីចោទប្រកាន់ប្រឆាំងនឹងអ្នកសារព័ត៌មាននិងការបោះពុម្ពផ្សាយរបស់ពួកគេអនុលោមតាមគោលការណ៍ទាំងនេះទេ៖ រាល់ការចោទប្រកាន់ទាំងនោះមិនបានអះអាង ឬឈានដល់គោលបំណងស្របច្បាប់ហើយក៏មិនមានភាពចាំបាច់សម្រាប់គោលបំណងបែបនេះ ដែលនាំអោយមានការរំលោភលើសិទ្ធិមនុស្សអន្តរជាតិនិងកាតព្វកិច្ចផ្លូវច្បាប់របស់កម្ពុជា។ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានអំពាវនាវឲ្យប្រទេសកម្ពុជា "បញ្ឈប់ការកាត់ទោសដល់អ្នកសារព័ត៌មាន ដែលជាមធ្យោបាយរារាំងឬបំបាក់ទឹកចិត្តពួកគេក្នុងការបញ្ចេញមតិដោយសេរី ។

យើងខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាឱ្យទម្លាក់ការចោទប្រកាន់ដោយគ្មានលក្ខខណ្ឌ និងដោះលែងអ្នកសារព័ត៌មានទាំងអស់ដែលជាប់ពន្ធនាគារដោយសារតែប្រើសិទ្ធិសេរីភាពបញ្ចេញមតិ បញ្ឈប់ការយាយីដល់អ្នកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន លុបចោលឬកែប្រែច្បាប់ដែលមានលក្ខណៈគាបសង្កត់ដើម្បីធ្វើឲ្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអាចដំណើរការបានដោយសេរី អនុលោមទៅតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ប្រទេសកម្ពុជា និងបញ្ឈប់ការដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដើម្បីជួយសម្រួលដល់សេរីភាពសារព័ត៌មាននិងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនិងព័ត៌មាន។

**សេចក្តីថ្លែងការណ៍នេះគាំទ្រដោយ៖**

១ សហគមន៍ដីធ្លី ១៩៧ ឃុំជីខលើ ខេត្តកោះកុង
២ មូលនិធិអន្តរជាតិសម្រាប់ការពារសេរីភាពបញ្ចេញមតិ
៣ អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់(កដទ)
៤ អង្គការលើកលែងទោសអន្តរជាតិ
៥ អង្គការមាត្រា ១៩
៦ អង្គការសមាជិកអាស៊ានសម្រាប់សិទ្ធិមនុស្ស (APHR)
៧ បណ្ដាញប្រជាធិបតេយ្យអាស៊ី (ADN)
៨ អង្គការវេទិកាអាស៊ីសម្រាប់សិទ្ធិមនុស្ស និងអភិវឌ្ឍន (FORUM-ASIA)
៩ បណ្ដាញអាស៊ីដើម្បីការបោះឆ្នោតដោយសេរី (ANFREL)
១០ សហគមន៍បឹងទន្លេម្រេច ខេត្តព្រះវិហារ
១១ សហគមន៍បឹងប្រាំ ខេត្តបាត់ដំបង
១២ សហគមន៍បឹងឈូក ភ្នំពេញ
១៣ សហគមន៍បឹងត្របែក ភ្នំពេញ
១៤ សហគមន៍បុរីកីឡា ភ្នំពេញ
១៥ សហគមន៍ប៊ូស្រា ខេត្តមណ្ឌលគិរី
១៦ អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)
១៧ សម្ព័នសហជីពកម្ពុជា (CATU)
១៨ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
១៩ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ
២០ សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
២១ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា អាដហុក (ADHOC)
២២ វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)
២៣ សម្ព័ន្ធអ្នកកាសែតកម្ពុជា (CamboJA)
២៤ បណ្ដាញយុវជនកម្ពុជា (CYN)
២៥ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស (CENTRAL)
២៦ សហគមន៍ដីធ្លីជីខក្រោម ខេត្តកោះកុង
២៧ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ

២៨ អង្គការការពារសិទ្ធិពលរដ្ឋ

២៩ សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)

៣០ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)

៣១ អង្គការសមធម៌កម្ពុជា (EC)

៣២ សហគមន៍បណ្តាញអតីតស្រ្តីបឹងកក់ ភ្នំពេញ

៣៣ អង្គការឃ្លាំមើលសិទ្ធិមនុស្ស

៣៤ សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)

៣៥ គណៈកម្មការអ្នកច្បាប់អន្តរជាតិ (ICJ)

៣៦ សហព័ន្ធអន្តរជាតិសម្រាប់សិទ្ធិមនុស្ស

៣៧ សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ

៣៨ អង្គការអោយហ្វិក

៣៩ វិទ្យាស្ថានសារព័ត៌មានអន្តរជាតិ

៤០ សេវាកម្មអន្តរជាតិសម្រាប់សិទ្ធិមនុស្ស

៤១ សហគមន៍ដីធ្លីឡពាង ខេត្តកំពង់ឆ្នាំង

៤២ សហគមន៍ការពារធនធានធម្មជាតិស្រុកក្រគរ ខេត្តពោធិសាត់

៤៣ សហគមន៍ដីធ្លីប៉ៃលិន

៤៤ មូលនិធិសារព័ត៌មានប៉ាគីស្ថាន

៤៥ PEN International

៤៦ សហគមន៍ភ្នំបាត

៤៧ សហគមន៍ភ្នំក្រោម ខេត្តសៀមរាប

៤៨ សហគមន៍ភូមិ២៣ ភ្នំពេញ

៤៩ សហគមន៍ព្រៃពាយ ខេត្តកំពត

៥០ សហគមន៍ជនជាតិដើមភាគតិចឃុំប្រមេរ ខេត្តព្រះវិហារ

៥១ សហគមន៍ផ្លូវរថភ្លើងទួលសង្កែ A

៥២ អង្គការអ្នកកាសែតគ្មានព្រំដែន (RSF)

៥៣ សហគមន៍ SOS ព្រលានយន្តហោះអន្តរជាតិភ្នំពេញ

៥៤ សហគមន៍ថ្មដា ខេត្តពោធិសាត់

៥៥ សហគមន៍ទួលសង្កែ B

៥៦ សហគមន៍ត្រពាំងសង្កែ ខេត្តកំពត

៥៧ អង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT)